សការព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០៤ លេខ ៦៦២ ចេញផ្សាយថ្ងៃ សៅរ៍ ទី ២២ ខែ ឧសភា ឆ្នាំ ២០១០

## លោក សម រង្ស៊ី ចូលរួមក្នុងពិធីកាន់ទុក្ខ លើកទី៦១នៃការបាត់បង់ទឹកដីកម្ពុជាក្រោម



ព្រះតេជគុណ គឹម មឿន, ញៀម គួន និងព្រះតេជគុណ ទឹម សាខន




លោក សម រង្ស៊ី ពេលជួបជាមួយពលរដ្ឋខ្មែរនៅក្រៅប្រទេសកន្លងមក

**ដោយ : ស្សាទរីយ៍**

ប្រធានគណបក្សប្រឆាំង នៃប្រទេសកម្ពុជាលោក*សម រង្ស៊ី*នឹងចូលរួមពិធីកាន់ទុក្ខ លើកទី៦១ នៃការបាត់បង់ ទឹកដីកម្ពុជាក្រោមដែលអាណានិគមនិយមបារាំងកាត់ឱ្យយួន កាលពីថ្ងៃទី៤ខែមិថុនា១៩៤៩។ យោងតាមការប្រកាស ឱ្យដឹង របស់សមាគម និងសាខា ខ្មែរកម្ពុជាក្រោម នៅតាមរដ្ឋ

**តទៅទំព័រទី៤ ច**

## តាមសម្តីជាមយៀបអ្នកស៊ីប្រាក់ខែមន្ត្រីរាជការ ខ្មោចជាង២លានដុល្លារក្នុងមួយឆ្នាំគ្មានទោសទេ



លោក ទៅ ហុងលី អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋាភិបាល



លោក ជាម យៀប

**ដោយ : ជ័យ តារា**

មន្ត្រីរដ្ឋាភិបាល បាននិយាយ ថា ពួកគេមិនច្បាស់ថា តើអ្នក ដែលទទួលប្រយោជន៍ ពីប្រាក់ ខែ មន្ត្រីរាជការខ្មោច នឹងត្រូវ ទទួលទោស ទៅតាមច្បាប់ ប្រឆាំងអំពើពុករលួយ ដែលទើប អនុម័តដែរឬយ៉ាងណាទេដែល

**តទៅទំព័រទី៤ ឡ**

## អង្គការអន្តរជាតិទិទៀនការតែងតាំង ឱម យ៉ិនទៀង ធ្វើប្រធានអង្គភាពប្រឆាំងនឹងអំពើពុករលួយ



លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីប្រទេសកម្ពុជា



លោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

**ដោយ : គ.អរពិន្ទ**

ប្រតិកម្មកាន់តែបង្ហាញនូវ ភាពក្តៅគុកគុកខ្លាំងឡើងពីសំណាក់ មន្ត្រីអង្គការសង្គមស៊ីវិលជាពិសេស អន្តរជាតិដោយទិទៀនការតែង តាំងលោក *ឱម យ៉ិនទៀង* ទីប្រឹក្សាពិសេសនាយករដ្ឋមន្ត្រី កម្ពុជាឱ្យកាន់តំណែងជាប្រធាន អង្គភាពប្រឆាំងអំពើពុករលួយ។ ហើយមជ្ឈដ្ឋានទាំងនេះហៅរក ការចូលរួមរបស់អង្គការសហ

**តទៅទំព័រទី២ ន**

## ករណីទំនាស់ដីធ្លីនៅឃុំអមលាំងខេត្តកំពង់ស្ពឺ គ្មានដំណោះស្រាយអ្វីទាំងអស់សម្រាប់អ្នកភូមិ

**ដោយ : ហង្ស ឧត្តម**

ទោះបីជាក្រុមបុគ្គលិកសិទ្ធិមនុស្សព្យាយាមបើកវេទិកាសាធារណៈមួយនៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដើម្បីស្វែងរកដំណោះស្រាយករណីទំនាស់ដីធ្លីរវាងអ្នកភូមិ និងក្រុមហ៊ុនឧកញ៉ា *លី យ៉ុងផាត់*

**តទៅទំព័រទី២ ស**



ប្រជាពលរដ្ឋនៅភូមិអមលាំងដែលតវ៉ាជាមួយក្រុមហ៊ុនលីយ៉ុងផាត់កន្លងមក

**ក្រុមហ៊ុនសំណង់ ថៃ ឡាគី នីហរ័ណ អាហរ័ណ**

THAY-LAKY IMPORT EXPORT AND CONSTRUCTION Co.,Ltd

**ក្រុមហ៊ុនមានទទួលសេវា ដូចតទៅ :**

☞ សាងសង់សំណង់គ្រប់ប្រភេទ (អគារ សណ្ឋាគារ រោងចក្រឧស្សាហកម្ម ឃ្លាំង ភូមិគ្រឹះ ផ្ទះល្វែង ស្ពាន ថ្នល់ ...)។
☞ សិក្សាគំរោង គូរប្លង់ គ្រឿងបង្គំ ស្ថាបត្យកម្ម ដោយកុំព្យូទ័រ ។
☞ លក់ ជួល ទិញ ផ្ទះ និង ដី ។ ☞ ដំឡើងបណ្តាញអគ្គិសនី ។
☞ ផលិតគ្រោងដែកសំណង់ ។ ☞ ទីប្រឹក្សាត្រួតពិនិត្យសំណង់។

ក្រុមហ៊ុនប្រជុំដោយ **អតីតសាស្ត្រាចារ្យ** វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (សាលាតិចណូ) វិស្វករសំណង់ស៊ីវិល ស្ថាបត្យករ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំ សាងសង់ត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស ។ សំណង់របស់លោកអ្នកប្រាកដជាមានភាពរឹងមាំ មានសោភ័ណភាពប្រកបទៅដោយ ផាសុកភាព និងមានសុភមង្គល។

អាស័យដ្ឋានផ្ទះលេខ ៨ ផ្លូវលេខ ៦១៨ សង្កាត់បឹងកក់ទី២ ខណ្ឌទួល គោក រាជធានីភ្នំពេញ។

Tel : (012) 954 606, (011) 527 767, (012) 862 515
: (012) 734 083, (012) 991 883, (012) 255 435
E-mail : thaylakyconstruction@yahoo.com
U.S.A : 5663 CHERRY AVE LONG BEACH, CA 908O5
E-mail : tanvuthay@verizon.net

## ពលរដ្ឋខ្មែរកម្ពុជាក្រោមទាំងក្នុងនិងក្រៅ ប្រទេសប្រជុំចជំស៊ីជានទៅនឹងក្មេងបៀមដៃ



លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី



ព្រះតេជគុណ យឿន ស៊ិន ព្រះចៅអធិការវត្តសាមគ្គីរង្សី



រូបថតវរជនខ្មែរកម្ពុជាក្រោមដែលត្រូវបានគេធ្វើពិធីរំលឹកជារៀងរាល់ឆ្នាំ



ទិដ្ឋភាពក្លោងទ្វារវត្តមួយក្នុងចំណោមវត្តជាច្រើនក្នុងទឹកដីខ្មែរកម្ពុជាក្រោម

**ដោយ : វាសនា**

នៅសល់ តែប៉ុន្មានថ្ងៃទៀត ពលរដ្ឋខ្មែរកម្ពុជាក្រោម ទាំងក្នុង និងនៅក្រៅ ព្រះរាជាណាចក្រកម្ពុជា នឹងរៀបចំពិធីកាន់ទុក្ខ ខួបលើកទី៦១ នៃការបាត់បង់ ទឹកដីកម្ពុជាក្រោម ដោយ សារអាណានិគម និយមបារាំង កាត់ទៅឱ្យយួន កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៤៩ ។

លោក *ផៃ ស៊ីផាន* អ្នកនាំ

**តទៅទំព័រទី២ ម**

### ដំណឹងលក់ដី

យើងខ្ញុំមានដីមួយកន្លែងទំហំ ៣០ម x ៣០ម នៅទល់មុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ ទីតាំងដីនោះនៅចម្ងាយប្រមាណ៥០០ម៉ែត្រពីភ្លើងស្តុបព្រលានយន្តហោះ ជាប់កាច់ជ្រុងផ្លូវបេតុង ស្ថិតនៅក្នុងភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានទឹក និងភ្លើងរដ្ឋ។

ទីតាំងនៃដីនោះស្ថិតនៅទីប្រជុំជន មានផ្សារ រោងចក្រ អាចធ្វើផ្ទះសំណាក់ ខុនដូ ហើយលក់ក្នុងតម្លៃ ៦៥ម៉ឺនដុល្លារអាមេរិក ដែលជាតម្លៃអាចនិយាយចរចាគ្នាបាន។ បើអតិថិជនចាប់អារម្មណ៍ សូមទំនាក់ទំនងទូរស័ព្ទលេខ **០១៦ ២៩ ៥៦ ៥៦**។

**សូមអរគុណ**

## ក្លឹបអ្នកកាសែតកម្ពុជាព្រួយបារម្ភពីសេរីភាព សារព័ត៌មានក្នុងកណ្តាប់ដៃតុលាការ

**ដោយ : វិសាល**

ថ្មីៗនេះអ្នកសារព័ត៌មាន ចំនួន៣នាក់ត្រូវបានសាលាដំបូង ខេត្តកំពង់ឆ្នាំងចេញដីកាបង្គាប់ ឱ្យចូលខ្លួនដើម្បីសាកសួរអំពី បណ្តឹងបរិហារកេរ្តិ៍ និងផ្សាយ ព័ត៌មានមិនពិត។

ក្នុងនោះមានភ្នាក់ងារសារ ព័ត៌មានកោះសន្តិភាព, កម្ពុជាថ្មី និងខ្មែរស្ថាបនា ដែលត្រូវ ប្រឈមនឹងការសាកសួរពីសំណាក់ មន្ត្រីតុលាការបន្ទាប់ពីមានពាក្យ បណ្តឹងរបស់ឈ្មោះ *នួន សុវណ្ណរិទ្ធ* ។

ទាក់ទិននឹងករណីខាងលើ នេះ ក្លឹបអ្នកកាសែតកម្ពុជា (ក.អ.ក) បានចេញសេចក្តីថ្លែង ការណ៍មួយកាលពីថ្ងៃទី២០ ខែ ឧសភាឆ្នាំ២០១០ដែលក្នុងនោះ ក.អ.ក បានសម្តែងនូវការ ព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា។

ជាមួយគ្នានេះដែរ ក.អ.ក បានថ្លែងនៅក្នុងសេចក្តីថ្លែង ការណ៍របស់ខ្លួនថា "*ក្លឹបអ្នកកាសែតកម្ពុជាបានតាមដានយ៉ាង*

**តទៅទំព័រទី៣ ខ**

*បរិយាយថ្ងៃនេះ*

## គណបក្សសមរង្ស៊ីរៀបចំវេទិកា ពន្យល់បច្ចេកទេសផែនទីបញ្ជាក់ថា យួនបោះបង្គោលរំលោភយកដីខ្មែរ

**ដោយ : ហង្ស ច្រាថ្នា**

បញ្ហាព្រំដែនរវាងប្រទេសកម្ពុជាជាមួយប្រទេសជិតខាងទាំង៣ ទាំងតំបន់ដែនគោក ទាំងតំបន់ដែនសមុទ្រ សូម្បីតែប្រទេសជិតខាងទាំងយួន សៀម និងលាវ ជាហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស២៣ តុលា ១៩៩១ ដែលមានករណីកិច្ចត្រូវអនុវត្តនិងគោរពអធិបតេយ្យភាពរបស់ប្រទេស

តទៅទំព័រទី៤ ក

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០២**
Tel: 017 360 678 , E-mail: kmsnews@gmail.com

**តមកពីទំព័រទី១ ស**

យ៉ាងណាក៏ដោយ ក៏នៅតែគ្មានលទ្ធផលអ្វីដែលគួរនឹងទទួលយកបានដែរ ។

កាលពីថ្ងៃព្រហស្បតិ៍ មន្ត្រីសិទ្ធិមនុស្សបានថ្លែងប្រាប់អ្នកសារព័ត៌មានថា នៅក្នុងវេទិកាសាធារណៈនោះគឺក្រុមអ្នកភូមិនៅមូលដ្ឋានបានច្រានចោលនូវការដោះស្រាយជាថ្មីរបស់រដ្ឋាភិបាល ។ ហើយដំណោះស្រាយដែលមន្ត្រីរដ្ឋាភិបាលបានលើកឡើងនោះ ក៏ផ្ទុយពីបំណងប្រាថ្នារបស់អ្នកភូមិថែមទៀតផង ។

ប្រតិកម្មរបស់អ្នកភូមិត្រូវបានលើកឡើងយ៉ាងក្ដៅគគុកមួយរំពេច ខណៈពេលដែលមន្ត្រីមូលដ្ឋានមួយរូបបាននិយាយតាមរបៀបអែបអបថា "*ដីធ្លីរបស់អ្នកភូមិពុំមានរងការប៉ះពាល់ដោយសារដីសម្បទានរបស់ឧកញ៉ា លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភានៃគណបក្សប្រជាជនកម្ពុជាឡើយ* "។

ជាក់ស្ដែងអភិបាលរងខេត្តកំពង់ស្ពឺមួយរូបឈ្មោះ *លឿង សុផាត* ដែលបានចូលរួមក្នុងវេទិកាសាធារណៈរៀបចំឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅឃុំអមលាំងបាននិយាយថា ក្រសួងកសិកម្មបានកាត់បន្ថយទំហំដីសម្បទានសម្រាប់ដាំដើមអំពៅរបស់ឧកញ៉ា *លី យ៉ុងផាត់* ១ម៉ឺនហិកតាមកនៅត្រឹម៨៣៤៣ហិកតាវិញ ។

លោក *លឿង សុផាត* បានបន្តនិយាយកោកៗទៀតថា "*ហើយពេលនេះក៏កំពុងកាត់បន្ថយដីសម្បទានទំហំ១ម៉ឺនហិកតារបស់ប្រពន្ធឧកញ៉ា លី យ៉ុងផាត់ ដែលនៅជាប់គ្នានេះឱ្យនៅសល់ត្រឹមតែ៧៤៦០ហិកតា ផងដែរ* "។

អភិបាលរងខេត្តកំពង់ស្ពឺរូបនេះបានព្យាយាមពន្យល់អ្នកភូមិបន្ថែមថា ក្រសួងកសិកម្មបានធ្វើបែបនេះដោយសារតែការព្រួយបារម្ភរបស់អ្នកភូមិដែលដីសម្រាប់ធ្វើកសិកម្មរបស់ខ្លួននឹងត្រូវរងផលប៉ះពាល់នោះ ។

ដោយឡែកលោក *លឿង សុផាត* នៅបានប្រាប់អ្នកភូមិដែលជាជនរងគ្រោះឱ្យដឹងពីផែនការសងជម្ងឺចិត្តរបស់ក្រុមហ៊ុនដែលត្រូវផ្ដល់ជូនអ្នកភូមិនូវដីសម្បទានសង្គមកិច្ចទំហំ៤២៤ហិកតានៅក្នុងឃុំរបស់អ្នកភូមិនិងដីទំហំ១០៤០ហិកតានៅឯតំបន់ព្រៃសហគមន៍មួយក្នុងឃុំត្រពាំងជោរ ។

ក្នុងនោះអភិបាលរងខេត្តកំពង់ស្ពឺនៅតែនិយាយយ៉ាងសឿងឃឿងគួរឱ្យអស់សំណើចថា អ្នកភូមិមិនត្រូវបានដាក់សម្ពាធដោយអាជ្ញាធរឬគម្រាមកំហែងដោយកម្លាំងទាហាននៅលើដីសម្បទានទាំងនោះទេ ។ ហើយថា គាត់ក៏មិនបានបង្ខំឱ្យអ្នកភូមិលក់ដីទៅឱ្យក្រុមហ៊ុនឬដោះដូរដីធ្លីនេះដែរ ពោលគឺវាអាស្រ័យលើអ្នកភូមិជាអ្នកសម្រេចចិត្តតែប៉ុណ្ណោះ ។

ប៉ុន្តែសម្រាប់អ្នកភូមិដែលបានចូលរួមក្នុងវេទិកាសាធារណៈនោះវិញបានអះអាងដូចៗគ្នាថា ពួកគាត់មិនចាប់អារម្មណ៍អ្វីនឹងការផ្ដល់ឱ្យដោយលោក *លឿង សុផាត* នោះទេ ព្រោះការផ្ដល់បែបនេះវាផ្ទុយពីបំណងប្រាថ្នារបស់ពួកគាត់ទាំងស្រុង ។

ជាមួយគ្នានេះអ្នកភូមិម្នាក់បានអះអាងឱ្យអ្នកសារព័ត៌មានដឹងថាអ្នកភូមិបានទាមទារការអនុញ្ញាតឱ្យពួកគាត់បានបន្តគ្រប់គ្រងលើដីបច្ចុប្បន្នរបស់ពួកគាត់ដដែលដោយគ្មានការផ្លាស់ប្ដូរអ្វីឡើយ ។

អ្នកភូមិម្នាក់ទៀតបានថ្លែងថា ពួកអាជ្ញាធរកំពុងបន្តដំណើរការវាស់វែងក្បាលដីមួយៗរបស់ប្រជាពលរដ្ឋទាំង៨៤២គ្រួសារនៅក្នុងតំបន់មានទំនាស់នេះដើម្បីកំណត់ថា តើដីអ្នកណាដែលកំពុងរងនូវផលប៉ះពាល់នោះ ?

កសិករម្នាក់ឈ្មោះ *ម៉ែន ប៉ោ* បានរៀបរាប់ពីដំណើររឿងដែលអ្នកភូមិបាននាំគ្នាក្រោកឈរប្រឆាំងជាមួយនឹងលោក *លឿង សុផាត* ខណៈពេលដែលបុរសមានអំណាចម្នាក់នេះព្យាយាមនិយាយដោយឥតអៀនខ្មាស់ថា ដីភូមិនេះនឹងមិនរងផលប៉ះពាល់ដោយសារតែដីសម្បទានរបស់ឧកញ៉ា *លី យ៉ុងផាត់* ទេ ។

កសិករ *ម៉ែនប៉ោ*បានបញ្ជាក់យ៉ាងដូច្នេះថា "*អ្នកភូមិបានប្រឆាំងតវ៉ាយ៉ាងពេញទំហឹងជាមួយចៅហ្វាយស្រុកថ្ពងឈ្មោះ សួន សុង ។ អ្នកភូមិបានបង្ហាញពីការក្ដៅក្រហាយខ្លាំងណាស់ ព្រោះអ្នកភូមិកំពុងតែរងគ្រោះនឹងការបាត់បង់ដីធ្លី តែបែរជាលោក សួន សុង និងលោក លឿង សុផាត និយាយផ្ដេសផ្ដាសទៅវិញ* "។

រហូតមកដល់ពេលនេះមិនទាន់មានដំណោះស្រាយណាមួយដែលត្រូវបានគេធ្វើឡើងនៅក្នុងវេទិកាសាធារណៈកាលពីថ្ងៃព្រហស្បតិ៍កន្លងមកនោះទេ ។ ហើយផ្ទុយទៅវិញ គឺមានតែធ្វើឱ្យប្រជាពលរដ្ឋនៅឃុំអមលាំងស្រុកថ្ពង ខេត្តកំពង់ស្ពឺទទួលរងនូវការឈឺចាប់មួយកម្រិតទៀត ។

លោក *ឈឹម សាវុធ* ដែលជាអ្នកសម្របសម្រួលរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានិងជាអ្នករៀបចំវេទិកានេះឡើងបានមានប្រសាសន៍ថាអាជ្ញាធរក្នុងមូលដ្ឋាននិងអ្នកភូមិប្រហែល៦០០នាក់បានចូលរួមក្នុងវេទិកាសាធារណៈនេះ ។ហើយក្នុងនោះក៏មានសមាជិកសភាមកពីគណបក្សនានាក៏បានចូលរួមដែរ លើកលែងតែសមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះដែលមិនហ៊ានលេចមុខទៅប្រឈមនឹងការពិតនោះ ។

លោក*ឈឹម សាវុធ* បានឱ្យដឹងទៀតថា ការផ្ដល់ជូនដោយមន្ត្រីរដ្ឋាភិបាលមិនត្រូវបានរាប់បញ្ចូលតាមការទាមទារណាមួយពីសំណាក់អ្នកភូមិក្នុងរឿងទំនាស់ដីធ្លីនេះទេ ។ ផ្ទុយទៅវិញក្រុមអាជ្ញាធរបែរជាប្រឹងប្រែងយ៉ាងសកម្មក្នុងការជួយក្រុមហ៊ុនរបស់ឧកញ៉ា*លី យ៉ុងផាត់*ដោយគ្មានការពិចារណាអ្វីឡើយ ។

ឥឡូវនេះក្រុមអ្នកតាមដាននានាកំពុងតែឃ្លាំមើលដោយយកចិត្តទុកដាក់បំផុតចំពោះដំណើររឿងដ៏អាស្រូវក្នុងករណីទំនាស់ដីធ្លីនៅឃុំអមលាំងរវាងប្រជាកសិករក្រីក្រនិងក្រុមហ៊ុនឧកញ៉ាមហាសេដ្ឋី *លី យ៉ុងផាត់* ជាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជាហើយៗសាច់រឿងនេះតើរដ្ឋាភិបាលដែលដឹកនាំដោយនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ត្រូវឈរខាងអ្នកណា ? ឈរខាងប្រជាកសិករ ឬឈរខាងឧកញ៉ា *លី យ៉ុងផាត់* ? ៕

---

**តមកពីទំព័រទី១ ន**

ប្រជាជាតិ និងម្ចាស់ជំនួយទាំងឡាយតាមដាន ទាំងការរឹងមាំនូវអង្គភាពប្រឆាំងនឹងអំពើពុករលួយកុំឱ្យមានការជ្រៀតជ្រែកលូកដៃពីអ្នកនយោបាយនៅកម្ពុជានោះ ។

បណ្ដាមន្ត្រីអង្គការសង្គមស៊ីវិលអន្តរជាតិនោះមានលោក *បេស៊ីល ហ្វែរណាន់ដូ* ប្រធានគណៈកម្មការសិទ្ធិមនុស្សអាស៊ីមូលដ្ឋាននៅហុងកុងបានហៅច្បាប់ប្រឆាំងនឹងអំពើពុករលួយនៅកម្ពុជាដែលចូលជាធរមាននោះថា ជាច្បាប់គួរឱ្យអស់សំណើច និងជាច្បាប់អន់ ។

លោក *បេស៊ីល ហ្វែរណាន់ដូ* ដែលជារឿយៗតាមដានស្ថានការណ៍សិទ្ធិមនុស្ស និងការវិវឌ្ឍន៍សង្គមសេដ្ឋកិច្ចនៅកម្ពុជាទាំងក្នុងអតីតកាលបានហៅអំណាចត្រួតត្រានៅកម្ពុជាដោយគណបក្សប្រជាជនថាធ្វើឡើង "*នៅក្រោមអំណាចកាំភ្លើង* " នោះ ថ្មីៗនេះនៅក្រោយការតែងតាំងលោក *ឱម យ៉ិនទៀង* ជាប្រធានអង្គភាពប្រឆាំងនឹងអំពើពុករលួយ សកម្មជនសិទ្ធិមនុស្សនេះហៅច្បាប់ថ្មីនៃកម្ពុជាថាជាច្បាប់ឆ្កួត ។

លោក *ហ្វែរណាន់ដូ* បានថ្លែងយ៉ាងនេះ "*នេះជាច្បាប់ឆ្កួតលីលាមួយ ហើយមិនមែនជាច្បាប់ត្រឹមត្រូវនោះឡើយ ។ អ្វីដែលត្រឹមត្រូវ គឺគេត្រូវការពារនិងរក្សាការសម្ងាត់ដល់អ្នកហ៊ានរាយការណ៍ពីអំពើពុករលួយ ។ អ្នកទាំងនោះត្រូវមានសេរីភាពបរិបូរណ៍ពីការភ័យខ្លាច ហើយក៏គ្មានការរងការផ្ដន្ទាទោស ឬដាក់ពិន័យពីករណីនៃការប្ដឹងអំពីអំពើពុករលួយឡើយ ។ដូច្នេះហើយខ្ញុំនិយាយថានេះជាច្បាប់ដែលគ្មានន័យខ្លឹមសារ ហើយជាច្បាប់ដ៏អាក្រក់* "។

ចំណែកឯមន្ត្រីជាន់ខ្ពស់នៃអង្គការឃ្លាំមើលសិទ្ធិមនុស្សពិភពលោកដ៏ធំមួយយូមែនរ៉ាយវ៉ចមានទីស្នាក់ការធំនៅរដ្ឋធានីវ៉ាស៊ីនតោនសហរដ្ឋអាមេរិកវិញ លោកស្រីបានបញ្ចេញប្រតិកម្មទិទៀនចំពោះការតែងតាំងលោក *ឱម យ៉ិនទៀង* ហើយថែមទាំងបានជម្រុញឱ្យប្រធានអង្គភាពប្រឆាំងនឹងអំពើពុករលួយតែងតាំងថ្មី គឺ *ឱម យ៉ិនទៀង* នេះប្រកាសអំពីទ្រព្យសម្បត្តិរបស់ខ្លួនជាមុនសិន មុននឹងកាន់ការនោះ ។

លោកស្រី *សូហ្វី រិឆាដសិន* នៃអង្គការយូមែនរ៉ាយវ៉ចបានមានប្រសាសន៍យ៉ាងនេះអំពី *ឱម យ៉ិនទៀង* "*គាត់ទំនងជាចូលចិត្តធ្វើការលើបញ្ហានេះ ។ មជ្ឈដ្ឋានទាំងឡាយចោទថា ឱម យិនទៀត ជាអ្នកធ្លាប់ប្រព្រឹត្តអំពើពុករលួយជាយូរមកហើយ ។ ដូច្នេះគាត់ពិតជាដឹងហើយអំពីអំពើពុករលួយ ។គាត់ត្រូវប្រកាសអំពីទ្រព្យសម្បត្តិរបស់គាត់ជាសាធារណៈជាមុនសិន មុននឹងធ្វើការងារនេះ* "។

រីឯអង្គការ Global Witness ដែលតាមដានយ៉ាងដិតដល់នូវដំណើរនៃការគ្រប់គ្រងប្រទេសកម្ពុជា ទាំងជាហូរហែធ្វើការសិក្សាស្រាវជ្រាវប្រមូលបាននូវឯកសារតឹកតាងមួយចំនួនចេញជារបាយការណ៍សាធារណៈផ្ដល់ជាអនុសាសន៍ដល់មេដឹកនាំកម្ពុជាកែលម្អស្ថានការណ៍អាក្រក់ទាំងឡាយក្នុងប្រទេសនោះ អង្គការមានមូលដ្ឋាននៅចក្រភពអង់គ្លេសក៏មានចំណែកនៅក្នុងប្រតិកម្មដ៏ខ្លាំងក្លាចំពោះការតែងតាំងលោក *ឱម យ៉ិនទៀង* នេះដែរ ។

លោក *ចច បូដិន* មន្ត្រីយុទ្ធនាការនៃអង្គការបរិស្ថានពិភពលោក Global Witness បានលើកហេតុផលអធិប្បាយថា កាលលោក *ឱម យ៉ិនទៀង* នៅធ្វើជាប្រធានគណៈកម្មការសិទ្ធិមនុស្សរបស់រដ្ឋាភិបាលនោះ ក៏មិនឃើញលទ្ធផលល្អប្រសើរអ្វីខាងផ្នែករំលោភសិទ្ធិមនុស្សនោះទេ ឃើញតែប្រជារាស្ត្ររងការរំលោភសិទ្ធិមនុស្សយ៉ាងច្រើន ។

លោក *ចច បូដិន* បានមានប្រសាសន៍ថា"*ខណៈដែលលោក ឱម យ៉ិនទៀង បំពេញតួនាទីជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្ស យើងឃើញមានបញ្ហាជាច្រើននៅក្នុងប្រទេសកម្ពុជា ដូចជាបញ្ហាដីធ្លី ការដេញប្រជារាស្ត្រពីលំនៅដ្ឋានដោយបង្ខំការពុំមានសំណងជួសជុលការខូចខាតសមរម្យ ការរឹតត្បិតសេរីភាពបញ្ចេញមតិជាដើម*"។

សម្រាប់អង្គការ Global Witness ជាផ្នែកមួយនៃអង្គការសង្គមស៊ីវិលអន្តរជាតិដែលសម្ដែងការព្រួយបារម្ភចំពោះការតែងតាំងលោក *ឱម យ៉ិនទៀង* ទីប្រឹក្សាជំនិតម្នាក់របស់នាយករដ្ឋមន្ត្រីកម្ពុជាឱ្យកាន់តំណែងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយនោះ Global Witness អធិប្បាយថា ដោយសារប្រវត្តិលោក*ឱម យ៉ិនទៀង* ធ្លាប់ធ្វើប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល ហើយមកកាន់តួនាទីជាប្រធានអង្គភាពថ្មីនេះ នោះវានឹងជាដំណើរបំផ្លាញដល់ភាពឯករាជ្យរបស់អង្គភាពប្រឆាំងនឹងអំពើពុករលួយរបស់ជាតិកម្ពុជា ។

លោក *ចច បូដិន* បានបន្តរៀបរាប់ថាការតែងតាំងមនុស្សនៅក្រោមអំណាចរបស់នាយករដ្ឋមន្ត្រីកម្ពុជាក្នុងរដ្ឋាភិបាលឱ្យដឹកនាំអង្គភាពប្រឆាំងនឹងអំពើពុករលួយ នឹងពុំមានប្រសិទ្ធិភាព ហើយក៏មិនមានការវែកញែកពួកមន្ត្រីពុករលួយដែលមានអំណាច ដែលអាចជាសាច់ញាតិរបស់នាយករដ្ឋមន្ត្រី ក៏ដូចជាឈ្មួញធំៗជាដើមនោះ ។

ជាបន្ថែមនោះ លោក *ចច បូដិន*បានកត់សម្គាល់ថា "*យើងមិនឃើញប្រទេសណានៅលើពិភពលោកតែងតាំងអ្នកនយោបាយឱ្យតាមដានស៊ើបអង្កេតអំពើពុករលួយក្នុងជួរមន្ត្រីរដ្ឋាភិបាលខ្លួនឯងឡើយ ។ ធ្វើដូច្នេះជាការអាចបំផ្លាញស្ថាប័នកំចាត់អំពើពុករលួយនេះតែម្ដង* "។

លោក *ឱម យ៉ិនទៀង* នេះត្រូវបាន Global Witness រាប់ឈ្មោះនៅក្នុងរបាយការណ៍របស់ខ្លួនចេញផ្សាយកាលឆ្នាំ២០០៩ ក្រោមចំណងជើងថា "*កម្ពុជាប្រទេសសម្រាប់ដាក់លក់* " ដោយបានធ្វើការចោទប្រកាន់ក្នុងឯកសារនោះថា *ឱម យ៉ិនទៀង* ជាអ្នកនៅពីក្រោយក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណរុករករ៉ែយ៉ាងច្រើនហើយក៏បានលុយយ៉ាងច្រើនសន្ធឹកសន្ធាប់ពីក្រុមហ៊ុនទាំងនេះ ទាំងមិនបង់លុយចំណែកណាចូលថវិការដ្ឋនោះទេ ។

មន្ត្រីអង្គការសង្គមស៊ីវិលកម្ពុជា ក៏ដូចជាមន្ត្រីអង្គការសង្គមស៊ីវិលអន្តរជាតិពិពណ៌នាច្បាប់ប្រឆាំងនឹងអំពើពុករលួយរបស់កម្ពុជាទើបបញ្ចេញក្រោយពីការផ្អើបទុក១៥ឆ្នាំដោយរដ្ឋាភិបាលបក្សប្រជាជននោះថា ច្បាប់នេះជាឧបករណ៍សម្រាប់រដ្ឋាភិបាលកាន់អំណាចប្រើប្រាស់ក្នុងការបំបិទមាត់ ក៏ដូចជាដាក់ទណ្ឌកម្មលើជនទាំងឡាយណាដែលហ៊ាននិយាយប្រឆាំងនឹងអំពើពុករលួយ ។

លោក*បេស៊ីល ហ្វែរណាន់ដូ* នៃអង្គការសិទ្ធិមនុស្សអាស៊ីបានអធិប្បាយថាដើម្បីឱ្យច្បាប់ប្រឆាំងនឹងអំពើពុករលួយយកទៅអនុវត្តបានប្រសើរឡើងនៅកម្ពុជានោះ ត្រូវតែមានស្ថាប័នឯករាជ្យមិននៅក្រោមអំណាចរដ្ឋាភិបាល ហើយមានថវិកាសកម្មភាពឯករាជ្យ ទាំងហ៊ានបំពេញតួនាទីស៊ើបអង្កេតដើម្បីចាប់ជនពុករលួយទាំងត្រូវការពារ ក៏ដូចជាលើកទឹកចិត្តដល់អ្នកដែលហ៊ានប្ដឹងអំពីករណីពុករលួយនោះ ។

សម្រាប់ Global Witness នោះអំណាចនយោបាយដ៏ជោគជាំនៅក្នុងកម្ពុជាដែលមនុស្សមួយក្រុមតូចសម្រេចអ្វីៗតាមឆន្ទៈរបស់ខ្លួន ហើយដែលបែបនេះអាចជ្រៀតជ្រែកដល់ការងារឯករាជ្យរបស់អង្គភាពប្រឆាំងនឹងអំពើពុករលួយនោះដំណោះស្រាយមានតែមួយច្រកប៉ុណ្ណោះ ។ Global Witness អធិប្បាយថា ផ្លូវដែលអាចធ្វើបាននោះ ដើម្បីបញ្ចៀស និងរារាំងការជ្រៀតជ្រែកពីអ្នកនយោបាយកាន់អំណាច គឺអង្គការសហប្រជាជាតិ ឬក៏ម្ចាស់ជំនួយអន្តរជាតិត្រូវផ្ដល់ការការពារឱ្យរឹងមាំដល់អង្គភាពប្រឆាំងនឹងអំពើពុករលួយ ហើយក៏មិនត្រូវឱ្យមន្ត្រីរដ្ឋាភិបាលធ្វើកិច្ចការនេះឡើយដែលជាការថ្លែងទិទៀនដល់ការកាន់តួនាទីរបស់លោក *ឱម យ៉ិនទៀង* ជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយនោះ ៕

---

**តមកពីទំព័រទី១ ម**

ពាក្យទីស្ដីការគណៈរដ្ឋមន្ត្រីបាននិយាយថា ទឹកដីកម្ពុជាក្រោមបានក្លាយទៅជា ទឹកដី របស់វៀតណាមនោះ តាំងពីក្រោយសង្គ្រាមលោកលើកទី២ម្ល៉េះ ។ ការអះអាងនេះ បានធ្វើឱ្យមន្ត្រីសង្ឃ មន្ត្រីអង្គការសមាគមខ្មែរកម្ពុជាក្រោម ទាំងក្នុងនិងក្រៅប្រទេសសំដែងការក្រេវក្រោធយ៉ាងខ្លាំង ហើយមន្ត្រីសង្ឃខ្លះបានប្រដូចលោក *ផៃ ស៊ីផាន* ថាជាមន្ត្រីខ្មែរអត់ដឹងស្អីសោះ និងថា សម្ដីនេះប្រៀបដូចជា ក្មេងបៀមដៃអញ្ចឹង ។

តាមរយៈ វិទ្យុសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោកដែលផ្សាយចេញ ពីសហរដ្ឋអាមេរិក ហើយត្រូវបានស្ដាប់ឮ នៅក្នុងទីក្រុងភ្នំពេញ តាមរយៈគេហទំព័រ www.khmerkrom.org កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១០,លោក *ផៃ ស៊ីផាន* បាននិយាយថា "*កម្ពុជាក្រោមយើងដឹងទាំងអស់គ្នាហើយតើមនុស្សមានដើមកំណើតជាខ្មែរ ប៉ុន្តែមិនមែននៅលើទឹកដីខ្មែរទេនៅលើទឹកដីវៀតណាម តាំងតែពីសង្គ្រាមលោកលើកទី២ យើងយល់ឃើញថា ដីនោះជាដីរបស់វៀតណាម* "។

ការនិយាយ របស់លោក *ផៃ ស៊ីផាន* នេះ បានធ្វើអោយមន្ត្រីសង្ឃ មន្ត្រីអង្គការសមាគមខ្មែរកម្ពុជាក្រោមទាំងក្នុង និងក្រៅប្រទេសមានប្រតិកម្មយ៉ាងខ្លាំង និងអ្នកខ្លះថា លោក *ផៃ ស៊ីផាន* ដែលជាអ្នកនាំពាក្យតំណាងឱ្យជាតិទាំងមូល មិនគួរនិយាយយ៉ាងដូច្នេះទេ ពីព្រោះទាំងខ្មែរកម្ពុជាក្រោម ក៏ដូចជាខ្មែរ នៅគ្រប់ទីកន្លែងទាំងអស់មិនទទួលស្គាល់បារាំង កាត់ដីខ្មែរ អោយទៅយួននោះទេ ។

ព្រះតេជគុណ ព្រះមហា *គ្រី សុវណ្ណ* ព្រះចៅអធិការវត្តជីឡូវ៉ែន ទីក្រុងមូឡៀល រដ្ឋអាឡាបាម៉ា និងជាអតីតនិស្សិត ពុទ្ធិកៈសាកលវិទ្យាល័យ ព្រះសីហនុរាជ រាជធានីភ្នំពេញមានសង្ឃដីកាប្រតិកម្មយ៉ាងដូច្នេះថា"*សម្ដីរបស់ឯកឧត្តមផៃ ស៊ីផានដែលជាតំណាង ឱ្យរដ្ឋាភិបាលកម្ពុជាទាំងមូល មានប្រសាសន៍យ៉ាងហ្នឹងគឺថា អាត្មា សូមកោតសរសើរមែនទែន ពីព្រោះគាត់ ជាអ្នកតំណាងអោយប្រទេសជាតិទាំងមូល មានប្រសាសន៍ យ៉ាងហ្នឹង ដូចជាក្មេងដែលមិនដឹងអ្វីទាំងអស់ ចំពោះប្រវត្តិសាស្ត្រភូមិសាស្ត្រ នៃប្រជាជាតិ ទាំងមូល* "។

ព្រះអង្គមានសង្ឃដីកាទៀតថា "*សូម្បីតែក្មេង រៀនសាលាបឋមសិក្សា ឬក៏មធ្យមសិក្សាឡើងទៅក៏ដឹងថាដីរបស់កម្ពុជានៅកន្លែងណាខ្លះ,ហើយនរណាខ្លះ បានប្លន់យកទឹកដី កម្ពុជាយើង ។ កម្ពុជាក្រោមគឺជាទឹកដីមួយល្បីសុះសាយ នៅទូទាំងសាកលលោក... ។ លោក ផៃ ស៊ីផានមានប្រសាសន៍បែបហ្នឹងគ្មានសមហេតុសមផល អ្វីទាំងអស់ ។ ចំពោះអាត្មា ដែលជា*

**តនៅទំព័រទី៣ ម**

តមកពីទំព័រទី១ ខ

យកចិត្តទុកដាក់ចំពោះករណីបណ្តឹងបរិហាកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតនេះ ហើយបានកត់សម្គាល់ថា បណ្តឹងនេះកើតមានក្រោយពេលដែលកាសែតកោះសន្តិភាព និងកាសែតកម្ពុជាថ្មី បានចុះផ្សាយអត្ថបទពាក់ព័ន្ធការកាប់បំផ្លាញព្រៃឈើរានយកដីនៅចំណុចអូររលុះស្ថិតក្នុងភូមិអញ្ចាញរូង ឃុំពេជចង្វា ស្រុកបរិបូរណ៍ខេត្តកំពង់ឆ្នាំង" ។

សេចក្តីថ្លែងការណ៍ដដែលនេះបានបន្តទៀតថា តាមអត្ថបទដែលបានចុះផ្សាយនោះ គឺក្លឹបអ្នកកាសែតកម្ពុជាពិនិត្យឃើញថា មានលក្ខណៈត្រឹមត្រូវតាមវិជ្ជាជីវៈ និងតាមការពិតជាក់ស្តែង ដែលមិនមានចំណុចណាមួយត្រូវប្តឹងពីបទបរិហាកេរ្តិ៍ ឬផ្សាយព័ត៌មានមិនពិតនោះឡើយ ។

ទោះជាដូច្នេះក្តី ក្លឹបអ្នកកាសែតកម្ពុជានៅតែអំពាវនាវដោយទទូចដល់សាលាដំបូងខេត្តកំពង់ឆ្នាំងឱ្យយកច្បាប់ស្តីពីរបបសារព័ត៌មានមកអនុវត្តចំពោះរឿងក្តីខាងលើនេះនិងប្រើប្រាស់សុភវិនិច្ឆ័យដើម្បីធានាថា សេរីភាពសារព័ត៌មាននៅកម្ពុជាមិនត្រូវបានរំលោភបំពាន ។ ហើយភ្នាក់ងារកាសែតកោះសន្តិភាព, កម្ពុជាថ្មី និងខ្មែរស្លាបនាត្រូវតែទទួលបាននូវភាពយុត្តិធម៌ ។

ក្នុងន័យនេះដែរ លោក *ហង្ស ចក្រា* ចាងហ្វាងកាសែត "*ខ្មែរម្ចាស់ស្រុក*" ដែលធ្លាប់ទទួលរងនូវការផ្តន្ទាទោសក្រោមច្បាប់ព្រហ្មទណ្ឌអន្តរកាលតាមបទចោទប្រកាន់ថា ផ្សាយព័ត៌មានមិនពិត និងបរិហាកេរ្តិ៍ជាប់ពន្ធនាគារអស់រយៈពេល៩ខែ ១៧ថ្ងៃក្នុងកំណត់ទោសរយៈពេល១២ខែនោះ ក៏បានអំពាវនាវដល់សាលាដំបូងខេត្តកំពង់ឆ្នាំងឱ្យយកច្បាប់ស្តីពីរបបសារព័ត៌មានមកអនុវត្តលើអ្នកកាសែតជាដាច់ខាត ។ ពិសេសគឺលោកមិនចង់ឃើញតុលាការប្រើប្រាស់អំណាចរបស់ខ្លួនជ្រុលហួសហេតុតទៅទៀតទេ ។

លោក*ហង្ស ចក្រា*បានថ្លែងកាលពីរសៀលម្សិលមិញថា លោកគាំទ្រទាំងស្រុងចំពោះសេចក្តីថ្លែងការណ៍របស់ក្លឹបអ្នកកាសែតកម្ពុជាហើយលោកនឹងបន្តតាមដានករណីបណ្តឹងនេះដើម្បីបញ្ជាក់ដោយច្បាស់លាស់ថា បណ្តឹងលើអ្នកកាសែតត្រូវតែទទួលបាននូវការដោះស្រាយដោយយុត្តិធម៌ ។

ខាងក្រោមនេះគឺជាសេចក្តីថ្លែងការណ៍របស់ក្លឹបអ្នកកាសែតកម្ពុជា ដែលយើងនឹងចុះផ្សាយតាមខ្លឹមសារដើមទាំងស្រុង ៕

### សេចក្តីកែតម្រូវ

ខ្ញុំ*ខែក វ៉ាន់ឌី*សូមអរគុណ *ខ្មែរម្ចាស់ស្រុក* ដែលបានសរសេរអំពីខ្ញុំ ។ ប៉ុន្តែខ្ញុំសូមកែតម្រូវថា សម្តេចឪ ព្រះមហាវីរក្សត្រ មិនបានតែងតាំងខ្ញុំធ្វើជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គទេ ៕


ក្លឹបអ្នកកាសែតកម្ពុជា
Club of Cambodian Journalists

សេចក្តីថ្លែងការណ៍

House N° 226, Street 155, Sangkat Tuol Tom Pong I, Khan Chamkarmom, Phnom Penh, Kingdom of Cambodia
Tel : (855-23) 224 094 / 012 267 277 / 012 895 853 / Fax : (855-23) 224 094
E-mail : ccj@online.com.kh , Website : ccj.com.kh

### សេចក្តីអំពាវនាវ

ស្ថិតក្នុងស្ថានភាពដែលសារព័ត៌មាន"ខ្មែរម្ចាស់ស្រុក" កំពុងជួបប្រទះនូវការខ្វះខាតហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ការបោះពុម្ពផ្សាយប្រចាំថ្ងៃបន្ទាប់ពីលោក ហង្ស ចក្រា ចេញពីពន្ធនាគារ ហើយនោះ គឺមានតែសមាណចិត្តរបស់មិត្តអ្នកអានជួយជាវសារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប៉ុណ្ណោះ។

សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" សូមថ្លែងអំណរគុណដល់ មិត្តអ្នកអានទុកជាមុនក្នុងការជួយជាវនេះ។ ព្រោះមានតែ មិត្តអ្នកអានហើយដែលអាចជួយឱ្យសារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ដំណើរការរឹងមាំបាន។

សូមអរគុណ

ផ្សព្វផ្សាយពាណិជ្ជកម្ម លើទំព័រសារព័ត៌មានខ្មែរម្ចាស់ស្រុក
សូមទាក់ទងមកកាន់
ទូរស័ព្ទ : 017 360 678 ទូរសារ : 023 987 411



តមកពីទំព័រទី២ ម

*កូនខ្មែរមួយរូបគឺថាអោយតម្លៃលោកផៃ ស៊ីផាន ស្មើនឹងក្មេងបៀមដៃម្នាក់... ។ យោបល់អាត្មាផ្ទាល់ សូមអោយលោកផៃ ស៊ី ផានហ្នឹង លាលែងចេញ ពីតំណែង ហើយចុះទៅ សិក្សាស្រាវជ្រាវឡើងវិញ ចំពោះទឹកដីប្រទេសកម្ពុជា... សូមលោកឈប់ កាន់តំណែងហ្នឹង តទៅទៀត*" ។

ព្រះតេជគុណ*ខេម ម៉ាណន់តូ* អតីតនិស្សិត ពុទ្ធិកៈវិទ្យាល័យសីនវង្ស នៃដែនដីកម្ពុជាក្រោម ដែលសព្វថ្ងៃ គង់នៅរដ្ឋ មីនីសូតា សហរដ្ឋអាមេរិក បានមានសង្ឃដីកា ប្រតិកម្មទៅនឹងសម្តីលោក *ផៃ ស៊ីផាន* យ៉ាងដូច្នេះថា "*យោបល់មួយ ដែលមិនសមស្រប ហើយកូនខ្មែរ ទាំងអស់ ដូចជាប្រជាជាតិខ្មែរទាំងមូល មិនយល់ស្រប តាមសម្តីរបស់លោកផៃ ស៊ីផាន និងមិនអាចទទួលយកបានឡើយព្រោះខ្មែរកម្ពុជាក្រោមទាំងអស់ រស់នៅលើទឹកដីកម្ពុជាក្រោម មិនដែលគិតថា ទឹកដីនេះ ជាទឹកដីរបស់យួន...ឬខ្មែរកម្ពុជាក្រោមទាំងមូល បានប្រគល់ទឹកដីនេះឱ្យទៅយួនម្តងណាទេ ។ មានតែការខំតស៊ូ រើបំរះ ស្ទិតស្ទាញ ទោះបីយួនធ្វើបាប ធ្វើទុក្ខ បុកម្នេញយ៉ាងណាក៏ដោយ ក៏ខ្មែរកម្ពុជាក្រោមនៅតែតស៊ូក្រាញនន្ទៀលស្ទិតស្ទាញដើម្បីតស៊ូនៅលើទឹកដី មាតុភូមិរបស់ខ្លួន ។ ប៉ុន្តែពេលនេះលោកផៃ ស៊ីផាន បានមានប្រសាសន៍ថា ទឹកដីកម្ពុជាក្រោម គឺជាទឹកដីវៀតណាម នៅក្នុងសង្គ្រាម លោកលើកទី២ គឺខ្មែរជាទូទៅ ទាំងខ្មែរ នៅក្រៅប្រទេស និងខ្មែរកម្ពុជាក្រោម នៅក្នុងប្រទេស មិនអាចទទួលយក ប្រសាសន៍លោកផៃ ស៊ីផានបានទេ*" ។

ព្រះអង្គ បានមានសង្ឃដីកាបន្តទៀតថា "*សម្តីលោកផៃ ស៊ីផាននេះ ប្រៀបដូចជា មនុស្សដែលមិនបានដឹងនូវអ្វីៗទាំងអស់នៅលើទឹកដី ខ្មែរកម្ពុជាក្រោម, ទឹកដីខ្មែរកម្ពុជាក្រោមគឺជាទឹកដីខ្មែរដដែល មិនមែនជា របស់វៀតណាមឡើយ ។ ហេតុនេះហើយ ប្រសាសន៍របស់លោកផៃ ស៊ីផាន គឺផ្ទុយនឹងមនសិការជាតិរបស់ខ្មែរទាំងមូល ។ កុំថាឡើយក្មេងបៀមដៃ ពីម្សិល ឬថ្ងៃនេះ ក៏អាចដឹងបានថាជាទឹកដីរបស់ខ្មែរ ហើយខ្មែរ រស់នៅលើទឹកដីខ្មែរស្របច្បាប់...យើងមិនបានចុះហត្ថលេខា ឬផ្តិតមេដៃឱ្យយួនម្តងណាទេ... ពលរដ្ឋខ្មែរកម្ពុជាក្រោមទាំងមូលទទួលរងនូវភាពវេទនា...*" ។

ព្រះតេជគុណ*ខេម ម៉ាណន់តូ* បានមានសង្ឃដីកាទៀតថាសម្តីរបស់លោក *ផៃ ស៊ីផាន* នេះមិនឱ្យខ្មែរទាំងនៅក្នុង និងនៅក្រៅប្រទេស ទទួលយកបានទេ ។ ព្រះអង្គបានបន្តថា "*លោកផៃ ស៊ីផាន មានប្រសាសន៍បែបនេះថា ទឹកដីខ្មែរកម្ពុជាក្រោមគឺជាទឹកដីរបស់យួននៅក្នុងសង្គ្រាមលោកលើកទី២ទៅហើយ ខ្មែរកម្ពុជាក្រោម រស់នៅក្រោមច្បាប់របស់យួន ។ ហេតុដូច្នេះ លោកផៃ ស៊ីផាន អាចនិយាយបានថា ថ្ងៃណាមួយ គាត់ក៏អាចនិយាយបានថា ទឹកដីខ្មែរ ទឹកដីកម្ពុជា ក៏ជាទឹកដី របស់យួនវៀតណាម យួនយៀកកុង នៅថ្ងៃណាមួយពុំខានឡើយ ព្រោះទឹកដីកម្ពុជា ក៏យួនយៀកកុងចូលមកត្រួតត្រា នៅសម័យឆ្នាំ១៩៧៩ ដូចគ្នានឹងទឹកដី កម្ពុជាក្រោមដែរ ។ ហេតុដូច្នេះ ពិតជាថ្ងៃណាមួយលោកផៃ ស៊ីផាននឹងថ្លែងថា ទឹកដីកម្ពុជា ជាទឹកដីរបស់យួន ពីព្រោះយួន បានចូលមកក្នុងទឹកដីខ្មែរ... ។ ខ្មែរយើងទាំងមូលពិតជារលំរលាយដោយសារពាក្យមួយម៉ាត់របស់លោកផៃ ស៊ីផាន...ឧទាហរណ៍យ៉ាងងាយយល់ថា ក្នុងសម័យគ្រានេះប្រៀបបានដូចជាលោកផៃ ស៊ីផាន ជាប្រពន្ធ របស់មានប់ម្នាក់ដែលដើរកាត់ព្រៃ ទៅជួបក្រុមចោរ ប្រពន្ធកាកេណី អប្រិយទុរិយស ជឿថាចោរស្រឡាញ់ខ្លួន ហុចដងឱ្យចោរ លុចផ្លែឱ្យប្តី ។ យ៉ាងណាមិញលោកផៃ ស៊ីផាន ប្រៀបបានដូចជាស្រីកាកេណី ហុចដងឱ្យចោរ ហុចផ្លែឱ្យប្តីយ៉ាងហ្នឹងឯង*" ។

សំរាប់ប្រជាពលរដ្ឋ និងមន្ត្រីអង្គការ សមាគម ខ្មែរកម្ពុជាក្រោម នៅទីក្រុងភ្នំពេញវិញក៏មានប្រតិកម្មខ្លាំងៗ ឆ្លើយតបទៅលោក *ផៃ ស៊ីផាន* ដែរ ។

លោកតូច ថឹង អនុប្រធានមជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោមបានប្រាប់*ខ្មែរម្ចាស់ស្រុក* តាមទូរស័ព្ទ នៅថ្ងៃម្សិលមិញ ពាក់ព័ន្ធនឹងសម្តី លោក *ផៃ ស៊ីផាន*យ៉ាងដូច្នេះថា "*ទឹកដីកម្ពុជាមិនមែនក្លាយទៅជាទឹកដីវៀតណាមដោយខ្មែរយើងយល់ព្រមនោះទេ គឺអាស្រ័យដោយ បារាំង កាត់ទៅឱ្យ អាណានិគមនិយមវៀតណាមដែលខ្មែរយើងមិនដែលយល់ព្រមទេ ពីព្រោះកាលៈទេសៈ គ្រប់កាលសម័យទាំងអស់ ខ្មែរយើង គ្រប់ពេលវេលា មិនដែលយល់ព្រមថា ដីនោះអោយយួនទេ... ។តែតាមគំនិតខ្មែរកម្ពុជាក្រោម គ្មានបំណង គ្មានគំនិតណាមួយ យល់ព្រមថា ទឹកដីនេះជាទឹកដីរបស់យួននោះទេ គឺជាទឹកដី របស់ខ្មែរយើងសុទ្ធសាធ*" ។

ព្រះតេជគុណ *យឿង ស៊ិន* ប្រធានសមាគមព្រះសង្ឃ ខ្មែរកម្ពុជាក្រោមបានមានសង្ឃដីកាប្រាប់ *ខ្មែរម្ចាស់ស្រុក* តាមទូរស័ព្ទ កាលពីម្សិលមិញ ពាក់ព័ន្ធនឹងសម្តីលោក *ផៃ ស៊ីផាន* យ៉ាងដូច្នេះថា "*រឿងហ្នឹង ត្រឹមត្រូវហើយ ពីព្រោះឆ្នាំ១៩៤៩ បារាំង បានកាត់ទឹកដី ខ្មែរកម្ពុជាក្រោមទៅអោយស្តេចយួន បាវដាយហ្នឹង អត់សួរយោបល់អ្នកម្ចាស់ស្រុក... ។ព្រះករុណាព្រះអង្គ ធ្វើព្រះរាជអន្តរាគមន៍ដែរ ប៉ុន្តែបារាំងអត់ស្តាប់ដោយសារបារាំងចាញ់ ឧបាយកលយួន ក៏កាត់ទឹកដីខ្មែរកម្ពុជាក្រោម ឱ្យទៅយួននៅឆ្នាំ១៩៤៩,បច្ចុប្បន្នកាលនេះចំនួន៦១ឆ្នាំហើយ... ។អាត្មារសាត់អណ្តែតមកដល់ព្រះរាជាណាចក្រកម្ពុជា...ក៏ដោយសារការឈឺចាប់នឹងការជិះជាន់សង្កត់សង្កិនរបស់យួន ប្រល័យពូជសាសន៍ខ្មែរទាំងអស់ ដើម្បីងាយស្រួលប្រើប្រាស់ទឹកដីខ្មែរកម្ពុជាក្រោម ។អាត្មាមានការឈឺចាប់ណាស់*" ៕

តមកពីទំព័រទី៤ ឡ

បាលនិងបុគ្គលិកទាំងឡាយណាដែលរកឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់ពុករលួយភ្លាមៗនោះទេ ដោយលោកបានលើកឡើងថា ពួកគេប្រហែលជាមិនដឹងថាខ្លួនពួកគេបានប្រព្រឹត្តខុសច្បាប់ផង ។

លោក*ជាម យៀប* បានថ្លែងដូច្នេះថា "*ដើម្បីការងារពង្រឹងច្បាប់ របស់យើង ជាជំហានដំបូងយើងគ្រាន់តែព្រមានបុគ្គលណាដែលបានយកប្រាក់ខែរបស់ឈ្មោះមន្ត្រីខ្មោចទាំងនោះសិន. យើងត្រូវធ្វើមួយជំហានម្តងៗ*" ។

ការនិយាយរបស់លោក*ជាម យៀប* នេះបញ្ជាក់ថាអ្នកដែលស៊ីប្រាក់ខែ មន្ត្រីរាជការខ្មោច ជាង២លានដុល្លារ ក្នុងមួយឆ្នាំទាំងនោះ នឹងគ្មានទោសទេ និងអ្នកដែលប្រព្រឹត្តនោះបានត្រឹមតែអប់រំប៉ុណ្ណោះ គឺវាផ្ទុយ អំពីច្បាប់ ប្រឆាំងអំពើពុករលួយដែលរដ្ឋសភា ទើបបានអនុម័តយ៉ាងតក់ក្រហល់ហើយនោះ ។

លោក*យឹម សុវណ្ណ* អ្នកនាំពាក្យគណបក្សសម រង្ស៊ី បានមានប្រសាសន៍ថា បើបទល្មើសដែលប្រព្រឹត្ត ដោយមន្ត្រីថ្នាក់ខ្ពស់ មិនត្រូវបានគេ អើពើនោះ ការកាត់ទោស មន្ត្រីថ្នាក់តូចតាចអាចមានផលអាក្រក់ច្រើនជាងល្អ ។ លោកបានមានប្រសាសន៍ថា "*សម្រាប់មន្ត្រីថ្នាក់តូច ការអប់រំគួរតែ ត្រូវប្រើសិន ហើយក្រោយមកបង្រៀនពួកគេម្តងហើយម្តងទៀតដើម្បីឱ្យពួកគេយល់ច្បាប់ ។ មន្ត្រីពុករលួយ ត្រូវតែនាំយក ទៅប្រឈមមុខនឹងច្បាប់ ចាប់ផ្តើមពីមន្ត្រីថ្នាក់កំពូលមុន ។ ពេលខ្លះពួកគេគ្រាន់តែ កាត់ទោសមន្ត្រីតូចតាច និងអំពើ ពុករលួយស្រាលៗតែប៉ុណ្ណោះ*" ។

ការបញ្ចេញរបាយការណ៍នៃការបាត់បង់ប្រាក់រដ្ឋ ប្រមាណជាង២លានដុល្លារ ទៅលើមន្ត្រីរាជការខ្មោចនេះ វាហាក់ដូចជាការងារយ៉ាងប្រញាប់ប្រញាល់មួយ រង់ចាំស្វាគមន៍លោក*ឱម យ៉ិនទៀង* ប្រធានអង្គភាពប្រឆាំងអំពើពុករលួយថ្មី ដែលជាមន្ត្រីដ៏មានទំនុកចិត្តរបស់លោក*ហ៊ុន សែន* នោះ ។ ដូច្នេះគេចាំមើលថាតើលោក*ឱម យ៉ិនទៀង*នឹងមានវិធានការយ៉ាងណាទៅលើពួកមន្ត្រីពុករលួយទាំងនោះដើម្បីទាក់ទាញការជឿជាក់ ពីអ្នកដែលរិះគន់លោកជុំទិស ពីការទទួលតំណែង ជាប្រធានគណៈកម្មការ ប្រឆាំងអំពើពុករលួយនេះ ។

ប៉ុន្តែការអះអាងរបស់លោក*ជាម យៀប* និងការមិនហ៊ាននិយាយ អំពីមន្ត្រីពុករលួយ ឱ្យស្របតាមច្បាប់ ប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភា ទើបតែបានអនុម័តនេះ បានបង្ហាញឱ្យឃើញថា អ្នកដែលកិបកេងប្រាក់រដ្ឋ ជាង២លានដុល្លារក្នុងមួយឆ្នាំនោះ នឹងគ្មានទោសទេ គឺពួកគេ បានត្រឹមតែទទួលបាននូវការអប់រំប៉ុណ្ណោះ ដែលវិធានការនេះ មិនអាចទប់ស្កាត់ អ្នកប្រព្រឹត្តអំពើពុករលួយបានទេ ។

សូមបញ្ជាក់ថា កន្លងមកប្រមុខរដ្ឋាភិបាលលោក*ហ៊ុន សែន* ធ្លាប់និយាយថា លោកមិនដឹងថា តើគេប្រព្រឹត្តអំពើពុករលួយរាប់លានដុល្លារយ៉ាងម៉េចទេបើអ្នកពុករលួយនោះ មិនបានបិទស្លាកនៅលើថ្ងាសថា ពួកគេប្រព្រឹត្តអំពើពុករលួយផងហ្នឹង ។

ប៉ុន្តែនៅពេលនេះ លោក*ង៉ោ ហុងលី* បានរកឃើញ អ្នកប្រព្រឹត្តអំពើពុករលួយ តាមរយៈនៃការស៊ីប្រាក់ខែ មន្ត្រីរាជការខ្មោចជាង២.០០០នាក់ ដែលធ្វើអោយរដ្ឋ ខាតបង់ប្រាក់ជាង២លានដុល្លារឯណោះនៅក្នុងមួយឆ្នាំៗនោះ តើលោក*ហ៊ុន សែន* មានវិធានការយ៉ាងណា ? ៕

ក្រុមហ៊ុនភាពយន្ត
ជនបទ
មានទទួលបញ្ចាំង
ខ្សែភាពយន្តខ្នាតធំ
ក្នុងពិធីផ្សេងៗ
មានពន្លឺច្បាស់
និងមានលក់ម៉ាស៊ីន
បញ្ចាំងខ្សែភាពយន្ត
ទំនាក់ទំនងតាមទូរស័ព្ទ
012 66 44 67
015 66 44 67

Tel: 017 360 678 , E-mail: kmsnews@gmail.com

តមកពីទំព័រទី១ ៩

នានា សហរដ្ឋអាមេរិក បានឱ្យដឹងថា ខ្មែរកម្ពុជាក្រោម នឹងជួបជុំគ្នាមួយ នៅថ្ងៃទី៥ មិថុនា ឆ្នាំ២០១០ នៅក្នុងវត្តនីតារ៉ាម នៃរដ្ឋហ្លរីដារ ដើម្បីរៀបចំពិធីកាន់ទុក្ខថ្ងៃបាត់បង់ទឹកដីកម្ពុជាក្រោម ដែលមានការចូលរួមពីលោក*សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី ផងដែរ ។

ចំណែកឯ នៅក្នុងរាជធានីភ្នំពេញវិញក៏មានការរៀបចំរំលឹកថ្ងៃបាត់បង់ទឹកដី កម្ពុជាក្រោម ផងដែរ ដែលលោក*ថាច់ សេដ្ឋា* ប្រធាន សហគមន៍ខ្មែរកម្ពុជាក្រោមតែងតែបានរៀបចំឡើងរៀងរាល់ឆ្នាំ គឺថ្ងៃទី៤ មិថុនា។

ពិធីដែលរៀបចំឡើង ដោយបងប្អូនខ្មែរកម្ពុជាក្រោម នៅឯអាមេរិកនោះក៏មានការចូលរួមពីឥស្សរជន ខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេសជាច្រើនរូបដូចជា លោក*ថាច់ កែប* ប្រធានវត្តនីតារ៉ាម, លោក*ដាញ់ តិច* ប្រធានសមាគមលោក*សឺងសឿង* ប្រធានសាខា នៃសហព័ន្ធ ខ្មែរកម្ពុជាក្រោមរដ្ឋហ្លរីដារ ។

សេចក្តីរាយការណ៍ បានឱ្យដឹងថា កម្មវិធីនោះ នឹងប្រព្រឹត្តទៅ រយៈពេល២ថ្ងៃ គឺចាប់ពីថ្ងៃទី៥-៦ ខែមិថុនា ២០១០ ខាងមុខនេះ នៅវត្តនីតារ៉ាមជារដ្ឋដែលប្រជុំ ទៅដោយបងប្អូនខ្មែរកម្ពុជាក្រោម ក្នុងទីក្រុងអូឡិនដូ រដ្ឋហ្លរីដារ សហរដ្ឋអាមេរិក ។

គណៈកម្មការ រៀបចំពិធីក៏បាននិមន្តព្រះតេជគុណ*ទឹម សាខន* អតីតព្រះចៅអធិការវត្តភ្នំដិនខាងជើង ខេត្តតាកែវនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ។ ព្រះអង្គត្រូវបានអាជ្ញាធខ្មែរចាប់ផ្សឹក កាលពីឆ្នាំ២០០៧ ហើយបញ្ជូនឱ្យអាជ្ញាធរយួន ដាក់ពន្ធនាគារ នៅខេត្តអាងយ៉ាង ប្រទេសយួន រួចបានដោះលែងឱ្យមានសេរីភាពវិញ បន្ទាប់ពីមានការថ្កោលទោស របស់អង្គការជាតិ និងអន្តរជាតិ ។ សព្វថ្ងៃព្រះអង្គបាននិមន្តចាកចេញទៅប្រទេសទីបី ដែលទទួលបាននូវកិត្តិយស និមន្តឱ្យចូលរួម នៅក្នុងពិធីកាន់ទុក្ខ នៃការបាត់បង់ទឹកដីកម្ពុជាក្រោម នៅសហរដ្ឋអាមេរិក ។

ពិធីនោះ មានការនិមន្តមន្ត្រីសង្ឃ ចំនួន២អង្គទៀតផងដែរ គឺព្រះនាម*ញ៉ែម តូន* និងព្រះតេជគុណ*គីម មឿន* ដែលតុលាការយួន បានដោះលែង កាលពីឆ្នាំ២០០៨ ហើយបានភៀសព្រះកាយទៅក្រៅប្រទេសសាងព្រះភ្នួសឡើងវិញ នៅវត្តមួយក្នុងទីក្រុងភីឡាឌែលហ្វា សហរដ្ឋអាមេរិកកាលពីសប្តាហ៍កន្លងទៅនេះ ។ នៅថ្ងៃទី២ នៃកម្មវិធីគឺពលរដ្ឋខ្មែរបានជួបជាមួយមន្ត្រីសង្ឃទាំងពារអង្គនេះ ដែលជាសាក្សីរស់ដោយផ្ទាល់ និងជាពិសេសនោះ ពលរដ្ឋខ្មែរយើងនឹងបានជួបសន្ទាដោយផ្ទាល់ ជាមួយលោក*សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី ។

យោងតាមការបញ្ជាក់របស់អ្នករៀបចំកម្មវិធីបានឱ្យដឹងថា លោក*អ៊ុំ សឿន* អតីតឯកអគ្គរាជទូតខ្មែរ ប្រចាំសហរដ្ឋអាមេរិក ក៏ចូលរួមស្តាប់ និងសន្ទនាដោយផ្ទាល់ ជាមួយលោក*សម រង្ស៊ី* ព្រះសង្ឃខ្មែរនិងបងប្អូនប្រជាពលរដ្ឋខ្មែរនៅទីនោះដែរ ។

ជាមួយគ្នានោះដែរ ក៏មានវេទិកាតុមូល សួរដេញដោលគ្នារវាងអ្នកចូលរួម ជាមួយលោក*សម រង្ស៊ី* អំពីស្ថានភាព នៃការបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាង ជាពិសេស ការបោះបង្គោលព្រំដែនជាមួយប្រទេសយួន ដែលធ្វើអោយប្រជាកសិករខ្មែរ រស់នៅ តាមតំបន់ព្រំដែននិយាយថាធ្វើឱ្យបាត់បង់ដីស្រែរបស់ពួកគាត់ ។

លោក*សម រង្ស៊ី* ក៏នឹងត្រៀមឯកសារ ភស្តុតាងដែលបញ្ជាក់ដោយសាស្ត្រា ជំនាញព្រំដែនជនជាតិស្វីសដើម្បីប្រាប់ដល់ប្រជាពលរដ្ឋខ្មែរនៅសហរដ្ឋអាមេរិកថា កម្ពុជាពិតបាត់បង់ទឹកដីរាប់រយម៉ែត្រ នៅក្នុងការបោះបង្គោលព្រំដែនជាមួយយួនត្រង់បង្គោលព្រំដែន លេខ១៨៤, ១៨៥, ១៨៦ និងលេខ១៨៧មែន ។ ជាមួយគ្នានោះផងដែរ លោក*សម រង្ស៊ី* នឹងបង្ហាញដល់ប្រជាពលរដ្ឋខ្មែរ ពាក់ព័ន្ធទៅនឹងការ ដកតម្រុយបង្គោល ព្រំដែនឈ្លានពាន លេខ១៨៥ ឱ្យពលរដ្ឋខ្មែរយើង បានឃើញឱ្យកាន់តែច្បាស់ ។

មន្ត្រីរដ្ឋាភិបាល តែងតែធ្វើការបដិសេធ ទៅនឹងព័ត៌មានដែលថាប្រទេសកម្ពុជាបាត់បង់ទឹកដី ដោយសារបោះបង្គោលព្រំដែនជាមួយប្រទេសជិតខាងយើង ។

ប៉ុន្តែ ក្រោយពីលោក *សម រង្ស៊ី* ដឹកនាំចលនាអ្នកភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ដកតម្រុយបង្គោល ព្រំដែនឈ្លានពាន លេខ១៨៥រួចមក, យួនបានដកគំរោងកសាងបង្គោលព្រំដែន លេខ ១៨៤, ១៨៦ និង១៨៧ យកទៅស្រុកគេវិញទាំងអស់ដោយបានគាស់ដែក និងជីកគ្រឹះ យកទៅវិញតែម្តង ។ ការដកបង្គោលព្រំដែន លេខ១៨៥នេះ បានធ្វើឱ្យនាយករដ្ឋមន្ត្រីយួនលោក*ង្វៀន តាន់ឌុង* អំពាវនាវឱ្យមេដឹកនាំខ្មែរមានវិធានការទៅលើលោក*សម រង្ស៊ី* ផងដែរ ។ ពេលនោះ តុលាការខ្មែរ ក៏ផ្តន្ទាទោសទៅលើលោក*សម រង្ស៊ី* និងអ្នកភូមិស្របគ្នានឹងការអំពាវនាវរបស់មេដឹកនាំយួននោះដូចចិត្ត ។

បញ្ហានេះបានធ្វើឱ្យមហាជនខ្មែរនិយាយថា បើគ្មានចលនាដឹកនាំដោយលោក*សមរង្ស៊ី*ដកតម្រុយ បង្គោលលេខ១៨៥ទេ ម៉្លោះយួន បោះបង្គោលព្រំដែនរួចរាល់ជាស្ថាពរធ្វើឱ្យខ្មែរយើងមិនអាចតវ៉ាបានឡើយ ៕

តមកពីទំព័រទី១ ឡ

បញ្ហានេះ បានបង្កើតឡើង ជាចម្ងល់ទៅលើការអនុវត្តន៍ច្បាប់ ដែលគេទន្ទឹមរង់ចាំ ជាយូរមកហើយនោះ ។

ប៉ុន្តែបើតាមការពន្យល់ ពីលោក*ជាម យៀប* មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន បានឱ្យដឹងថា អ្នកដែលស៊ីប្រាក់ខែ ពីមន្ត្រីរាជការខ្មោច ដែលធ្វើឱ្យរដ្ឋខាតបង់ថវិកា ប្រមាណ ២ លានដុល្លារ ក្នុងមួយឆ្នាំនោះនឹងគ្មានទោសទេ, ហើយលោក*ឱម យ៉ិន ទៀង* ប្រធានគណៈកម្មការប្រឆាំង អំពើពុករលួយថ្មីដែលទើបបានតែងតាំងនឹងមានវិធានការយ៉ាងណា បើអំពើពុករលួយលេចចេញយ៉ាងក្រឡៅៗឱ្យសាធារណៈជន បានដឹងទៅហើយនោះ ។

ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី២១ ឧសភា ២០១០ បានស្រង់សម្តីលោក*ង៉ោ ហុងលី* អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នៃទីស្តីការ គណៈរដ្ឋមន្ត្រី ដែលនិយាយថា ជំរឿនមន្ត្រីរាជការស៊ីវិល ដែលចាប់ផ្តើមកាលពីខែមុនបានរកឃើញមន្ត្រីរាជការខ្មោចឬបុគ្គលិករដ្ឋដែលបានលាឈប់ពីការងារតែនៅមានឈ្មោះ ក្នុងតារាងបើកប្រាក់ខែ ប្រមាណ២.០០០នាក់ក្រោយពេលបញ្ចប់ការរាប់ក្នុងក្រសួង ស្ថាប័ន រដ្ឋាភិបាលចំនួន ២១ ក្នុងចំណោមក្រសួងសរុបចំនួន២៦ ។

លោកមិនយាយ អំពីមន្ត្រីពុករលួយដែលទទួលបានប្រាក់ខែពីមន្ត្រីរាជការខ្មោចទាំងអស់នោះ ត្រូវមានទោសតាមច្បាប់ប្រឆាំងអំពើពុករលួយ ឬយ៉ាងណាទេ ។ បើទោះបីជា លោក*ង៉ោ ហុងលី* បានលើកឡើងថា ឈ្មោះមន្ត្រីខ្មោច ដែលបានរាប់រួចរាល់ មកទល់នឹងពេលនេះ ធ្វើឱ្យរដ្ឋខាតបង់ប្រាក់ប្រមាណ ២លានដុល្លារអាមេរិកក្នុងមួយឆ្នាំក៏ដោយនោះ ។

លោក*ជាមយៀប* សមាជិកសភាគណបក្សប្រជាជនមណ្ឌលព្រៃវែងបានថ្លែងថា ច្បាប់ប្រឆាំងអំពើពុករលួយ មានចែងអំពីបញ្ហានេះ ។ លោកបានគូសបញ្ជាក់ថា បើបុគ្គលណា ត្រូវបានរកឃើញថា លួចប្រាក់ខែរបស់មន្ត្រីរាជការខ្មោច ដាក់ចូលហោប៉ៅផ្ទាល់ខ្លួន ច្បាប់បានចែងថា ព្រះរាជអាជ្ញាមានសិទ្ធិដាក់ពាក្យបណ្តឹងដើម្បីដាក់ទណ្ឌកម្មដល់បុគ្គលនោះ ។ លោកបានបន្តថា លោកមិនគិតថា វាជាពេលវេលាសមរម្យសម្រាប់ដាក់ទោសទណ្ឌ លើមន្ត្រីរដ្ឋាភិ

តទៅទំព័រទី៣ ឡ




តមកពីទំព័រទី១ ក

កម្ពុជាក៏ដោយនោះ នៅតែជារឿងដែលទាំងគណបក្សសម រង្ស៊ី ទាំងសកម្មជនព្រំដែនកម្ពុជានៅលើឆាកអន្តរជាតិ ទាំងអ្នកសង្កេតការណ៍បរទេសជាពិសេសប្រជារាស្ត្រខ្មែរជាសាក្សីរស់នៅតំបន់ទាំងនោះផងអធិប្បាយថា ការដោះស្រាយធ្វើឡើងដោយយឺត និងជាការចាញ់ប្រៀបរបស់ប្រទេសកម្ពុជាជាមួយប្រទេសជិតខាងទាំងនេះ។ ករណីដ៏លេចធ្លោរមួយគឺលោក សម រង្ស៊ី សមាជិកសភាកម្ពុជាកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ រួមជាមួយប្រជារាស្ត្រម្ចាស់ដីស្រែដែលមានបង្គោលតម្រុយព្រំដែនបោះដាំនៅលើដីខ្មែរទាំងនោះ អស់លោក លោកស្រីបានដកតម្រុយបង្គោលទាំងនោះចេញពីដីខ្មែរតំបន់ជាយដែន។ រឿងនេះក៏ផ្តើមឱ្យមានការខឹងសម្បារយ៉ាងខ្លាំងរបស់នាយករដ្ឋមន្ត្រីយួនង្វៀនតាន់ឌុងដែលបញ្ចេញប្រតិកម្មទាមទារឱ្យរដ្ឋាភិបាលកាន់អំណាចនៅកម្ពុជាចាត់វិធានការប្រឆាំងនឹងលោក សម រង្ស៊ី ក៏ដូចជាប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែ។

មែនដូចចិត្ត នៅថ្ងៃទី១៦ ខែវិច្ឆិកា ប្រហែល៣សប្តាហ៍ក្រោយការដកបង្គោលតម្រុយនោះ និងនៅបន្ទាប់ពីនាយករដ្ឋមន្ត្រីយួនបានទាមទារយ៉ាងនោះគណបក្សកាន់អំណាចនៅកម្ពុជា ទាំងក្នុងជួររដ្ឋាភិបាល ទាំងក្នុងជួរសភាជាតិបានប្រើវិធានការដកព្យួរអភ័យឯកសិទ្ធិសភាលោក សម រង្ស៊ី រួចកាត់ទោសលោកកំបាំងមុខ ទាំងកាត់ទោសប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែរងគ្រោះដាក់ពន្ធនាគារ។ ហើយរឿងនេះក៏កំពុងបានទាក់ទាញការយកចិត្តទុកដាក់តាមដានយ៉ាងជិតដល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ទាំងសហរដ្ឋអាមេរិក សហភាពអន្តរសភានៃប្រទេសចំនួនជាង១៣០លើពិភពលោក ទាំងសហភាពអឺរ៉ុបផង។

តើបង្គោលតម្រុយព្រំដែនដែលលោក សម រង្ស៊ី និងប្រជាកសិករបានដកចេញពីដីស្រែរបស់អ្នកស្រី មាស ស្រី និងលោក ព្រំ ជា ជាម្ចាស់ដីនោះ បង្គោលទាំងនោះបោះដាំនៅលើដីខ្មែរដូចប្រជារាស្ត្រជាសាក្សីជាម្ចាស់ដីបានអះអាង ឬមួយក៏មានការភ័ន្តច្រលំនឹងរាប់ចំណែកនោះថាជារបស់វៀតណាម ហើយក៏មានការបោះបង្គោលតម្រុយបែបនោះជាមួយវិធានការសកម្មភាពនៃអំណាចរបស់គណបក្សប្រជាជនត្រួតត្រាកម្ពុជាគាបសង្កត់ប្រជារាស្ត្រ និងបើកយុទ្ធនាការប្រឆាំងនឹងលោក សម រង្ស៊ី និងគណបក្សសមរង្ស៊ីនោះ ?

មានការងឿងឆ្ងល់យ៉ាងច្រើនថា ចុះបើលោក សម រង្ស៊ី ក៏ជាខ្មែរ ហើយកសិករទាំងនោះជាអ្នកកាន់កាប់ដីធ្វើស្រែពីដូនតារាប់ទសវត្សរ៍មកក៏ជាខ្មែរ និងដែលនាយករដ្ឋមន្ត្រីទាំងមេដឹកនាំគណបក្សប្រជាជនជាខ្មែរគិតដល់ការការពារបូរណភាពទឹកដីជាតិកម្ពុជាដូចតែគ្នាមែន ហេតុអ្វីចាំបាច់ខឹងតូងតាំងធ្វើតាមការប្តឹងរបស់នាយករដ្ឋមន្ត្រីយួនប្រាថ្នាចាប់លោក សម រង្ស៊ី ដាក់ពន្ធនាគារ ក៏ដូចជាចាប់ប្រជាកសិករខ្មែរម្ចាស់ដីស្រែដាក់គុកបែបនេះ? ហេតុអ្វីក៏អ្នកកាន់អំណាចនៅកម្ពុជារដ្ឋាភិបាលគណបក្សប្រជាជន ទាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនប្រើវិធីត្រជាក់អន្ទងប្រមូលគ្នាមកពិនិត្យពិភាក្សាដើម្បីឱ្យដឹងការពិតថាធ្វើយ៉ាងណាបើពិតជាការបោះបង្គោលតម្រុយនោះមិនធ្វើឱ្យវៀតណាមបានប្រៀបកេងចំណេញយកដីខ្មែរ ហើយកម្ពុជាជាអ្នកខាតបង់ដូចការអះអាងរបស់ប្រជារាស្ត្រនៅតំបន់ជាយដែន ?

រឿងនេះគេត្រូវការនូវអ្នកជំនាញឯកទេសភូមិសាស្ត្រ និងផែនទីដើម្បីនឹងអាចបញ្ជាក់ ហើយក៏ជាការដែលលោក សម រង្ស៊ី បាននឹងកំពុងបន្តប្រឹងប្រែងដែលមានការចូលរួមរបស់អ្នកជំនាញវិទ្យាសាស្ត្រ បច្ចេកទេសភូមិសាស្ត្រនិងផែនទីអន្តរជាតិនៃប្រទេសស្វីស និងអាមេរិក ទាំងគណកម្មាធិការព្រំដែនកម្ពុជាដឹកនាំដោយលោក ស៊ាន ប៉េងសែ កំពុងខំប្រឹងយ៉ាងខ្លាំង។ ដើម្បីគោលដៅនេះគណបក្សសមរង្ស៊ីបាននឹងកំពុងរៀបចំទស្សនកិច្ចជូនលោកស៊ាន ប៉េងសែ និងគណកម្មាធិការព្រំដែនជួបសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិកដើម្បីនឹងធ្វើការពន្យល់បច្ចេកទេសថា ទឹកដីខ្មែរតំបន់ជាយដែនខាងកើតជាមួយវៀតណាមជាង១២០០គីឡូម៉ែត្រពិតជាមានចំណែកដែលបាត់បង់ ហើយទីតាំងភូមិសាស្ត្រដែលលោក សម រង្ស៊ី និងប្រជាកសិករខ្មែរដកបង្គោលតម្រុយចេញ គឺជាចំណុចស្ថិតនៅក្នុងបូរណភាពនៃទឹកដីកម្ពុជា និងមិនគួរជាទីតាំងនៃការបោះបង្គោលតម្រុយព្រំដែនកម្ពុជា-វៀតណាម ដូចការអនុវត្តរបស់គណកម្មាធិការព្រំដែនប្រទេសទាំងពីរនោះទេ។

លោក ស៊ាន ប៉េងសែ ដែលកំពុងបំពេញទស្សនកិច្ចជួបសហគមន៍ខ្មែរនៅតាមបណ្តារដ្ឋនានានៃសហរដ្ឋអាមេរិកតាមការរៀបចំរបស់គណបក្សសមរង្ស៊ីនោះ លោកបានថ្លែងក្នុងនាមជាអ្នកបច្ចេកទេសផែនទី និងជាសាក្សីរស់ដ៏សំខាន់ម្នាក់ស្គាល់ទីតាំងភូមិសាស្ត្រទឹកដីខ្មែរតំបន់ព្រំដែនយ៉ាងច្បាស់នោះថា "ជាការជាក់ស្តែងណាស់ យួនបោះបង្គោលព្រំដែនក្នុងដីខ្មែរពីព្រោះក្នុងឆ្នាំ១៩៩៥យួនធ្វើឱ្យយើងទាំងអស់យល់ច្រឡំពីកន្លែងបោះបង្គោល កន្លែងណាទៅកន្លែងណាតាំងពីខាងជើងរហូតដល់មកខាងត្បូងហើយផែនទីយួនគេធ្វើឱ្យមកក្នុងព្រំប្រទល់ដែនជាង១២០០គីឡូម៉ែត្រដែលមានផែនទីបារាំងបន្សល់ទុកឱ្យ២៦ផ្ទាំង និង៤០ផ្ទាំងទៀតជាផែនទីដែលយួនធ្វើក្នុងឆ្នាំ១៩៦០ និងផែនទីសហរដ្ឋអាមេរិកធ្វើក្នុងឆ្នាំ១៩៧០។ ដូច្នេះផែនទីយួន ផែនទីអាមេរិកាំងទាំងអស់ ខ្មែរយើងមិនដែលទទួលស្គាល់ទេ (Sic)"។

លោក ស៊ាន ប៉េងសែ បានអធិប្បាយយោងទៅដល់រដ្ឋធម្មនុញ្ញច្បាប់កំពូលរបស់ប្រទេសកម្ពុជាដែលចែងថា បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាមានទំហំ១៨១០៣៥ គីឡូម៉ែត្រការ៉េ ផ្អែកលើផែនទីបារាំងធ្វើពីឆ្នាំ១៩៣៣ដល់ឆ្នាំ១៩៥៣ ហើយជាមួយគ្នានេះលោកក៏លើកជាចំងល់ថា ហេតុអ្វីសន្និសញ្ញាខ្មែរ-យួនសព្វថ្ងៃយកផែនទីទាំងអស់មកលាយឡំគ្នាដូចជាសម្លកកូរ មានផែនទីឥណ្ឌូចិន-បារាំង ផែនទីអាមេរិកាំងផង ផែនទីយួនផង ? ដូច្នេះបែបនេះបានជាវាមានការបោះបង្គោលចូលមកក្នុងដីខ្មែរ ហើយបើមានផែនទីតែមួយវាមិនមានបញ្ហាអ្វីដូច្នេះទេ"។

លោកបានលើកចង្អុលករណីដែលកម្ពុជាក្នុងសម័យសង្គមរាស្ត្រនិយមដឹកនាំដោយព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ កាលកណ្តាលទសវត្សរ៍ទី៥០មកដល់ដើមទសវត្សរ៍ទី៦០បានប្រើផែនទីតែមួយគត់ដែលមានតម្កល់ទុកនៅអង្គការសហប្រជាជាតិ។ ប៉ុន្តែករណីព្រំដែនកម្ពុជាជាមួយយួនត្រូវលោក ស៊ាន ប៉េងសែ លើកអធិប្បាយថា ហេតុអ្វីក៏គេមិនយកផែនទីដែលបារាំងទុកឱ្យជំនាន់ឆ្នាំ១៩៦៣ ដល់១៩៦៧ ដែលយួនក៏ទទួលស្គាល់នោះ ? ហើយហេតុអ្វីក៏យកផែនទីដែលយួនធ្វើឆ្នាំ១៩៧០ និងអាមេរិកាំងធ្វើឆ្នាំ១៩៦៧មកឱ្យកម្ពុជាទទួលស្គាល់ទៅវិញដែលនេះពន្យល់ដល់ហេតុអ្វីបានជាប្រទេសកម្ពុជាថាបាត់បង់ទឹកដី និងចាញ់ប្រៀបប្រទេសវៀតណាមក្នុងការបោះបង្គោលព្រំដែននោះ៕